កញ្ចប់

ស្តង់ដារពិការភាព
សំរាប់ការអប់រំ

ធ្វើការជាមួយគ្នា: ឆ្លងកាត់អនុវិទ្យាល័យ

ធនធាននេះគាំទ្រសិស្សដែលមានពិការភាព និងមាតាបិតានិងអ្នកថែរក្សា ដែលឆ្លងពីសាលាបឋមសិក្សាទៅអនុវិទ្យាល័យ និងផ្លូវនានាបន្ទាប់ពីសាលា។

ធនធាននេះត្រូវបានផ្នែករួមគ្នាដោយសិស្សនិងក្មេងដែលមានពិការភាព និងមាតាបិតា និងអ្នកថែរក្សារបស់គេ។

អំពីធនធាននេះ

ធនធាននេះត្រូវបានទទួលមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។ វាត្រូវបានឆ្នែដោយសិស្សនិងក្មេងដែលមានពិការ ភាពនិងមាតាបិតានិងអ្នកថែរក្សារបស់គេ រួមនឹងជំនួយពី**កុមារនិងយុវជនដែលមានពិការភាពអូស្ត្រាលី** (Children and Young People with Disability Australia - CYDA) ហើយនិង**ការរាប់បញ្ចូលអូស្ត្រាលី** (Inclusion Australia)។

រដ្ឋាភិបាលអូស្ត្រាលីទទួលស្គាល់ម្ចាស់ទឹកដីដើមនិងអ្នកថែរក្សាប្រទេសទូទាំងប្រទេសអូស្ត្រាលី។ យើងទទួលស្គាល់ដល់ទំនាក់ទំនងដ៏និរន្តន៍ជាមួយដី ទឹក និងសហគមន៍របស់គេ។ យើងសូមគោរពដល់ពួកគេនិងដល់ពួកចាស់ទុំពីអតីតកាលនិងបច្ចុប្បន្នកាល។ យើងសូមគោរពដល់ការអនុវត្តផ្នែកវប្បធម៌ ព្រលឹងវិញ្ញាណ និងការអប់រំនៃជនអាបូរិជិនល និងពួកកោះTorres Straight។

កំណត់សំគាល់ពីភាសា

ធនធាននេះប្រើភាសាបុគ្គលមុន (ឧ. 'ក្មេងដែលមានពិការភាព')។ ប៉ុន្តែវិធីនេះមិនសមនឹងមនុស្សគ្រប់រូប ហើយមនុស្សជាច្រើនចូលចិត្តភាសាអត្តសញ្ញាណមុន (ឧ. សិស្សពិការ)។

វាសំរេចទៅលើបុគ្គលម្នាក់ៗ ដែលគេជ្រើសរើសសំគាល់ខ្លួនដោយរបៀបណានោះ។ យើងសូមលើកទឹកចិត្តអ្នកអោយសួរគេថាគេចូលចិត្តអ្វី។ យើងក៏ទទួលស្គាល់ប្រវត្តិសាស្ត្រដ៏ជ្រាលជ្រៅដែលនៅពីក្រោយពាក្យទាំងនេះដែរ។

ធនធាននេះគឺសំរាប់សិស្សដែលមានពិការភាព និងមាតាបិតានិងអ្នកថែរក្សារបស់គេ។ យើងប្រើពាក្យ 'កូនរបស់អ្នក' គឺមានន័យថាកូនណាដែលអ្នករ៉ាប់ទទួលខុសត្រូវ។

ពាក្យ 'ការកែសំរួលសមហេតុសមផល' 'ការកែសំរួល' ឬ'ការបំពេញបំណង' ត្រូវបានគេប្រើសំដៅទៅលើន័យតែ មួយ។ យើងប្រើពាក្យទាំងនេះឆ្លុះគ្នាក្នុងធនធាននេះ។ 'ការកែសំរួលសមហេតុសមផល' ត្រូវបានប្រើក្នុងច្បាប់*ស្តង់ ដារពិការភាពសំរាប់ការអប់រំ ២០០៥ (Disability Standards for Education 2005).*

ធនធានបន្ថែម

ស្កេនកូដ QR

នេះគឺមួយផ្នែកនៃធនធានមួយក្រុម។ អ្នកអាចរកឃើញនៅក្នុងវ៉ែបសៃត៍នៃក្រសួងអប់រំ ឬដោយស្កេនកូដ QR។

ធនធាននេះក៏មាននៅក្នុង Easy Read, Auslan និងភាសាផ្សេងៗមួយចំនួនទៀត។ អ្នកអាចចូលមើលសំណេរទាំងនោះនៅវ៉ែបសៃត៍ Australian Government Department of Education ឬ ដោយស្កេនកូដ QR។

កំណត់សំគាល់មាតិកា: *កញ្ចប់ឧបករណ៍នេះមាននិយាយពីអារម្មណ៍ភ័យ ហើយនិងការមានបញ្ហានៅសាលា។ សំរាប់ជំនួយគាំទ្រ សូមទូរស័ព្ទមក Lifeline តាមលេខ* ***13 11 14*** *ឬផ្ញើសារតាមលេខ* ***0477 13 11 14****. អ្នកក៏ អាចទាក់ទង Kids Helpline តាមលេខ* ***1800 55 1800****.*

កញ្ចប់ឧបករណ៍នេះសំរាប់អ្នកណា

កញ្ចប់ឧបករណ៍នេះគឺសំរាប់:

- សិស្សអនុវិទ្យាល័យដែលមានពិការភាព។
- ឪពុកម្តាយនិងអ្នកថែរក្សារបស់សិស្សអនុវិទ្យាល័យដែលមានពិការភាព។

កញ្ចប់ឧបករណ៍នេះគឺសំរាប់អ្វី

កញ្ចប់ឧបករណ៍នេះគឺសំរាប់ជួយអ្នកអោយ:

- យល់អំពីសិទ្ធិរបស់អ្នកក្រោមច្បាប់ *ស្តង់ដារពិការភាពសំរាប់ការអប់រំ ២០០៥ (Disability Standards for Education 2005)*។
- ធ្វើការជាមួយគ្នា និងជាមួយសាលារបស់អ្នកដើម្បីជួយគាំទ្រការអប់រំរបស់អ្នក។

កញ្ចប់ឧបករណ៍នេះផ្តែងអំពីអ្វីខ្លះ

កញ្ចប់ឧបករណ៍នេះគឺស្តីអំពីការធ្វើការជាមួយគ្នាពីដើមលុះដល់ចប់អនុវិទ្យាល័យ។ វាផ្តែងអំពី:

- ស្តង់ដារពិការភាពសំរាប់ការអប់រំ ២០០៥ (ទំព័រ ១)
- ឆ្លងអនុវិទ្យាល័យ (ទំព័រ ២)
- ចាប់ផ្តើមចូលអនុវិទ្យាល័យ (ទំព័រ ៥)
- ធ្វើការសំរេចចិត្តពេលនៅសាលា (ទំព័រ ៧)
- លាចាកសាលា (ទំព័រ ៩)

ស្តង់ដារពិការភាពសំរាប់ការអប់រំ ២០០៥ (DSE)

អ្វីទៅជាស្តង់ដារពិការភាពសំរាប់ការអប់រំ 2005?

ស្តង់ដារ DSE ជាស្តង់ដារសំរាប់អប់រំសិស្សដែលមានពិការភាព។

ស្តង់ដារ

ស្តង់ដារជាអ្វីដែលយើងប្រើសំរាប់វាស់ថាអ្វីដែលបានធ្វើគឺល្អប៉ុណ្ណា។
ស្តង់ដារជួយអោយយើងធ្វើយ៉ាងណាអោយអ្វីៗដើរបានល្អ។

ស្តង់ដារ DSE

ស្តង់ដារ DSE ពន្យល់នូវប្រការសំខាន់ពីរយ៉ាង:

1. សិទ្ធិរបស់សិស្សដែលមានពិការភាព
2. សាលាត្រូវធ្វើដូចម្តេចខ្លះដើម្បីជួយសិស្សដែលមានពិការភាពអោយទទួលសិទ្ធិរបស់គេ។

+ ឆ្លងកាត់អនុវិទ្យាល័យ

ការចាប់ផ្តើមឬឆ្លងកាត់អនុវិទ្យាល័យជាការឆ្លងដ៏ធំមួយ។
ការឆ្លងកាត់គឺនៅពេលអ្នកវើពីចំណុចមួយទៅចំណុច មួយទៀត។ នៅសាលាមានការឆ្លងកាត់ច្រើន។

ឧទាហរណ៍:



ត្រប់គ្នាមានការឆ្លងកាត់ខុសៗគ្នា។

អ្នការមែង:

- ធំលូតលាស់
- រៀនត
- ចង់ដឹងថាអ្នកអាចធ្វើអ្វីបានខ្លះ ហើយមានចំណុចខ្លាំងអ្វីខ្លះ។

ចូរចងចាំថាអនុវិទ្យាល័យជាការធ្វើដំណើរមួយ

ដំណើរអនុវិទ្យាល័យរបស់អ្នកចាប់ផ្តើមនៅពេលអ្នកចេញពីសាលាបឋមសិក្សា។ វាចប់ពេលអ្នកចប់សាលា។

ទោះបើអ្នកនៅទីណាក្នុងការធ្វើដំណើររបស់អ្នក សាលារបស់អ្នកត្រូវ:

- ជួយគាំទ្រអ្នកអោយចូលរួមហើយរៀន
- ដាក់វិធានការដើម្បីបង្ការអ្នកមិនអោយគេធ្វើបាប។

ការកែសំរួលសមហេតុផល

សាលាអ្នកត្រូវផ្តល់ការជួយគាំទ្រដែលអ្នកត្រូវការដើម្បីចូលរួមនិងរៀន។ នេះមានន័យថា គេត្រូវធ្វើការផ្លាស់ប្តូរដែលជួយអ្នកអោយចូលរួមជាមួយមិត្តស្រករៗនឹងអ្នក។ ការផ្លាស់ប្តូរទាំងនេះគឺហៅថា ការកែសំរួលសមហេតុផល។

ការកែសំរួលសមហេតុផលជាអ្វីទៅ?

បណ្តាសាលាទាំងឡាយអាចមានឈ្មោះផ្សេងសំរាប់ហៅការកែសំរួលសមហេតុផល - ឧ. ការបំពេញបំណង ឬការគាំទ្រ។ ទាំងនោះគឺសុទ្ធតែជាការផ្លាស់ប្តូរដែលជួយអោយអ្នកចូលរួមជាមួយមិត្តស្រករៗនឹងអ្នក។ ការកែសំរួលអាចជា:

- បណ្តាជន (ឧ. ក្រូគាំទ្រ)
- ប្រដាប់ប្រដា (ឧ. ប្រដាប់អានអេក្រង់)
- ការផ្លាស់ប្តូរក្នុងរបៀបធ្វើអ្វីមួយ (ការសំរាកក្នុងពេលប្រឡង)។

អ្នកអាចសេតអាប់ការគាំទ្រ:

- ពេលសាលាចាប់ផ្តើមបើកបង្រៀន
- ពេលមានអ្វីផ្លាស់ប្តូរក្នុងជីវិតអ្នក
- ពេលមានអ្វីផ្លាស់ប្តូរនៅសាលា។

អ្នកអាចយល់ដឹងថែមទៀតអំពី:

- សិទ្ធិរបស់អ្នកក្នុងវីឌីអូរបស់យើងឈ្មោះ មួយថ្ងៃនៅសាលា (A day at school)
- របៀបដែលគេគួរគោរពអ្នកនៅសាលាក្នុងធនធានរបស់យើងឈ្មោះ ការគោរពនៅសាលា (Respect at school)។

អ្នកគួរធ្វើការជាមួយគ្នា

ក្នុងហាន:ជាមាតាបិតាឬអ្នកថែរក្សា អ្នកគួរធ្វើការ:

- ជាមួយកូនអ្នកដើម្បីអោយបានយល់ពីតំរូវការ និងជំរើសរបស់គេ
- ជាមួយសាលាដើម្បីរៀបចំនិងសង្កេតមើលការគាំទ្រ។

អាចផ្ញើអ៊ីមេលតែមួយឬប្រជុំតែម្តងគឺគ្រប់គ្រាន់ហើយ។ ឬក៏អាចត្រូវប្រជុំពីរបីដង។

ក្នុងហាន:ជាសិស្ស អ្នកគួរមានឱកាសដើម្បី:

- ចែករំលែកគំនិតយោបល់ និងមតិរបស់អ្នក
- ទៅប្រជុំពីការអប់រំរបស់អ្នកបើអ្នកចង់
- សាកល្បងអ្វីមួយ ហើយផ្លាស់ប្តូរតាមចិត្ត។
-

តើអ្នកត្រូវការជំនួយលើផ្នែកទាំងនេះទេ?

បរិស្ថានដែលប៉ះពាល់បាន?
ឧ. ថ្នាក់រៀន អាគារ ឬទីលេងកំសាន្ត

ការងារសាលា?
ឧ. ប្រដាប់ប្រដាសំរាប់ថ្នាក់រៀន សកម្មភាព អាសាញមិន ឬការប្រឡង

ការទាក់ទងគ្នា?
ឧ. ការសរសេរ ការនិយាយ ការមើល ឬការស្តាប់

សង្គមនិងមនោសញ្ចេតនា? ឧ. អ្នកមានអារម្មណ៍ឬប្រស្រ័យយ៉ាងណាជាមួយអ្នកដទៃ ឬទីកន្លែងនានា

ជាការល្អដែលសិស្ស មាតាបិតា និងអ្នកថែរក្សានាំគ្នាគិតពីសំណួរនេះ។ នោះអ្នកអាចបញ្ចេញគំនិត យោបល់នៅពេលមកប្រជុំជាមួយសាលា។

អ្នកអាចយល់ដឹងថែមទៀតអំពីជំនួយគាំទ្រក្នុងធនធានរបស់យើងដែលមានឈ្មោះថា ការពន្យល់ពីស្តង់ដារពិការភាពសំរាប់ការអប់រំ។

ចាប់ផ្តើមអនុវិទ្យាល័យ

ការឡើងថ្នាក់ទៅអនុវិទ្យាល័យអាចជាការដ៏ធំមួយ។ ជាការរំភើបចិត្តណាស់ដែល ចាប់ផ្តើមដំណើរនេះ។ ក៏មានការផ្លាស់ប្តូរច្រើនណាស់ដែរ ហើយនិងមានការរៀបចំច្រើនទៀតផង។

ក្នុងនាមជាសិស្ស អ្នកនឹង:

- កសាងលើអ្វីដែលបានរៀនពីសាលាបឋមសិក្សា
- ជួបគ្រូនិងមិត្តរួមថ្នាក់ថ្មី
- ស្គាល់អាគារនិងដីធ្លីថ្មី
- រើសយកមេរៀនថែម
- មានអាសាញមិននិងការប្រឡង

អ្នកអាចមានអារម្មណ៍ភិតភ័យអំពីការផ្លាស់ប្តូរនេះ។ នេះគឺធម្មតាទេ។ វាត្រូវការពេលដើម្បីសំរួល។

គន្លឹះសំរាប់ធ្វើការជាមួយគ្នា

សំរាប់សិស្ស

- *ចូរបើកចំហអំពីអារម្មណ៍ដែលអ្នកមាន។* កុំលាក់បាំងឡើយបើអ្នកព្រួយបារម្ភ ឬមានសំណួរ។
- *ចូរប្រាប់គេអោយដឹងបើមានអ្វីដែលមិនមានដំណើរការសំរាប់អ្នក។* នេះអាចជាការងារសាលារបស់អ្នក ការសេតអាប់ថ្នាក់រៀនរបស់អ្នក ឬអ្វីផ្សេងទៀត។ សាលាអ្នកគួរគាំទ្រអ្នកអោយចូលរួម។ អ្នកអាចសូមអោយគេផ្លាស់ប្តូរបាន វាមិនធ្វើទេ។
- *ចូរចែករំលែកអ្វីដែលកើតឡើងនៅសាលាជាមួយមនុស្សពេញវ័យដែលអ្នកទុកចិត្ត។* យ៉ាងនេះគាត់នឹងដឹងអំពីអ្វីដែលកើតឡើង។ ជាទង្វើដែលជួយគាត់អោយជួយអ្នក។

សំរាប់មាតាបិតានិងអ្នកថែរក្សា

- *ចូរនិយាយអំពីការឆ្លងពីបឋមសាលាទៅអនុវិទ្យាល័យថាវានឹងទៅជាយ៉ាងណា និងពីអ្វីដែលនឹងកើតឡើង។*
- *ចូរស្វែងយល់អំពីសាលានិងអ្វីដែលកូនអ្នកនឹងធ្វើ។* នោះអ្នកនឹងអាចឆ្លើយសំណួរកូនរបស់អ្នកបាន។
- *ចូរចាប់ផ្តើមការសន្ទនាមុនពេលចូលសាលា។* អ្នកអាចយកកូនអ្នកទៅសាលាមុននឹងចូលរៀនអោយគេស្គាល់សាលានិងគ្រូៗទាំងឡាយ។
- *ចូរពន្យល់ពីការគាំទ្រឬការកែសំរួល។* ជួយកូនអ្នកអោយយល់ពីរបៀបចូលសាលា អោយគេដឹងថានឹងប្រទះអ្វីខ្លះ។
- *ចូរដាក់គោលដៅជាមួយកូនអ្នក។* គាត់ចង់បានអ្វីខ្លះ? តើគាត់នឹកស្រមៃនឹងធ្វើអ្វីខ្លះសំរាប់ពេលវេលានៅសាលា? ចូរចាំគោលដៅទាំងនេះពេលអ្នកទៅជួបជាមួយសាលា។
- *ចូរលើកទឹកចិត្តកូនអ្នកអោយប្រាប់ពីអ្វីដែលកើតឡើងនៅសាលា។* ចូរឆែកមើលផងថាតើកូនអ្នកមាន អារម្មណ៍ថាអ្នកគាំទ្រគាត់ឬអត់។ អ្នកអាចសួរសំណួរបើមានបារម្ភ ឬបើចង់ឆែកពីវឌ្ឍនភាពរបស់កូនអ្នក។
- *សូមប្រាប់សាលាអោយដឹងបើអ្វីៗមិនមានដំណើរការ។* សួរកូនអ្នកថាតើគាត់ចង់អោយសាលាដឹងពីអ្វីខ្លះ។

អ្នកអាចយល់ដឹងថែមទៀតអំពី:

- ការឆ្លងទៅអនុវិទ្យាល័យក្នុងធនធានរបស់យើងឈ្មោះ បង្គោលសំខាន់និងការឆ្លង
- រាប់បញ្ចូលកូនអ្នកក្នុងការសន្ទនាទាំងនេះក្នុងធនធានរបស់យើងឈ្មោះ គាំទ្រជាមួយនិងគាំទ្រ អោយកូនអ្នក: សាលាបឋមសិក្សា។

ធ្វើការសំរេចចិត្តក្នុងអំឡុងពេលនៅសាលា

ក្នុងអំឡុងពេលនៅសាលា អ្នកត្រូវធ្វើការសំរេចចិត្តច្រើន។

នេះអាចចាប់ផ្តើមតាំងតែពីថ្នាក់៧។ អ្នកប្រហែលអាចជ្រើសរើសមេរៀនដែលអ្នកនឹងរៀន។

ការសំរេចចិត្តទាំងនេះគឺដូចជាការមកដល់ផ្លូវបែកជាពីរ។ អ្នកជ្រើសរើសផ្លូវមួយឬជំរើសមួយទៀតដើម្បីតាម។ ផ្លូវនេះនឹងនាំអ្នកទៅកន្លែងដែលអ្នកចង់ទៅ។ អ្នកមិនគួរអោយគេរុញទៅតាមផ្លូវជំរើសរបស់អ្នកដទៃឡើយ។ អ្នកមានសិទ្ធិដល់ជំរើសគ្រប់យ៉ាង។
បន្ទាប់ពីសាលាចប់ អ្នកអាចសំរេចចិត្តចូល:

អ្នកអាចបញ្ចូលជំរើសទាំងនេះចូលគ្នាបាន។ អ្នកក៏អាចដូរចិត្ត ហើយប្តូរបាន។
ទោះជាសំរេចចិត្តយ៉ាងណា អ្នកគួរ:

- ទទួលការរាប់បញ្ចូលដោយអ្នកដែលនៅជុំវិញអ្នក
- មានការជ្រើសរើសដូចមិត្តស្រករនឹងអ្នកដែរ។

អ្នកអាចប្រើសំណួរទាំងនេះដើម្បីចាប់ផ្តើមគិតអំពីជំរើសរបស់អ្នក:

- អ្នកចូលចិត្តមេរៀនអ្វីខ្លះ?
- តើចំណុចខ្លាំងនិងចំណូលចិត្តរបស់អ្នកគឺអ្វីខ្លះ?
- ការងារអ្វី ឬអាជីពអ្វីដែលអ្នកចូលចិត្ត?
- តើការរៀនប្រភេទណាដែលអ្នកចូលចិត្ត?
- តើត្រូវដាក់ផែនការអ្វីខ្លះដើម្បីតាមចំណូលចិត្តទាំងនេះ?
- តើជំហាននីមួយៗពាក់ព័ន្ធអ្វីខ្លះ?
- តើមានអ្វីដែលអ្នកត្រូវដាក់ផែនការអោយហើយសិនឬអត់?
- តើអ្នកបានធ្វើការងារដើម្បីយកបទពិសោធន៍ហើយឬនៅ? បើបានធ្វើហើយ តើអ្នកបានយល់ដឹងអ្វីខ្លះអំពីខ្លួនឯង?

អ្នកប្រហែលត្រូវការធ្វើការស្រាវជ្រាវខ្លះៗតាមដំណើររបស់អ្នក។

គន្លឹះសំរាប់ធ្វើការជាមួយគ្នា

សំរាប់សិស្ស

- *អ្នកមានសមត្ថភាពដើម្បីធ្វើការជ្រើសរើសទាំងនេះ។* ចូរគិតពីអ្វីដែល*អ្នក*ចង់អោយបានកើតឡើង។
- *ចូរស្វែងរកជំនួយឬឱ្យវាទបើអ្នកត្រូវការ។* អ្នកអាចរកជំនួយពីអ្នកដែលទុកចិត្តម្នាក់។ នេះអាចជាមិត្ត ឪពុកម្តាយ អ្នកថែរក្សា ឬគ្រូ។
- *បើមានការមិនច្បាស់ប្រាកដឬមានអារម្មណ៍លិចលង់ នោះមិនថ្ងៃទេ។* កុំលាក់ - ចូប្រាប់គេហើយពិភាក្សាគ្នា។

សំរាប់មាតាបិតានិងអ្នកថែរក្សា

- *អោយកូនអ្នកសំរេចចិត្តតាមចិត្តដែលគាត់ចង់ធ្វើ។* កុំធ្វើការជ្រើសរើសអោយគាត់។
- ចូរគាំទ្រកូនអ្នកបើគាត់សួររកជំនួយ។ អ្នកអាចចែករំលែកមតិឬជួយគាត់ដាក់ផែនការ។ អ្នកអាចពន្យល់ពីផ្លូវផ្សេងៗហើយថា ផ្លូវនោះនឹងនាំទៅណា។
- កុំខ្លាចនឹងផ្តល់ជំនួយ។ កុំចាំដល់កូនមកសួរ។

លាចាកសាលា

មានផ្លូវប្លែកៗគ្នាច្រើនដែលអ្នកឈានទៅបានបន្ទាប់ពីសាលា។ កញ្ចប់ឧបករណ៍នេះផ្តោតទៅលើផ្លូវនានានៃការអប់រំ។

ការលាចាសាលាគឺជាការផ្លាងដ៏ធំមួយ។

អ្នកនឹង:

- មានការផ្លាស់ប្តូរយ៉ាងខ្លាំងដល់កិច្ចការប្រចាំរបស់អ្នក
- យល់ដឹងនិងសិក្សាតាមវិធីប្លែកៗ
- ស្គាល់អាគារនិងជីវិតថ្មីៗ
- មានទំនាក់ទំនងឧបសគ្គជាមួយគ្រូៗរបស់អ្នក។

ការផ្លាស់នេះអាចបណ្តាលអោយអ្នកផ្លាស់ប្តូរកន្លែងរស់នៅ។

គន្លឹះសំរាប់ធ្វើការជាមួយគ្នា

មុនដំបូង សូមឆែកមើលគន្លឹះសំរាប់:

- ចាប់ផ្តើមសាលាបឋមសិក្សា (ទំព័រ ៥)
- ធ្វើការសំរេចចិត្តក្នុងអំឡុងពេលនៅសាលា (ទំព័រ ៧)

សំរាប់សិស្ស

- គេអោយអ្នកមានម្ចាស់ការលើខ្លួនឯងជាងមុន។ គេក៏អោយអ្នកទទួលការគាំទ្រផងដែរ។ អ្នកមិនបាច់ធ្វើអ្វីតែម្នាក់ឯងទេ។
- អ្នកអាចយល់ដឹងថែមទៀតអំពីការផ្លាស់ក្នុងធនធានរបស់យើង ឈ្មោះ ស្តង់ដារពិការភាពសំរាប់ការអប់រំក្នុងការអនុវត្ត: គំរោងចាត់ការ។

សំរាប់មាតាបិតានិងអ្នកថែរក្សា

- *ចូរគាំទ្រកូនអ្នកអោយមានម្ចាស់ការលើខ្លួនឯងថែមទៀត។* ការមានម្ចាស់ការប៉ុណ្ណានោះគឺអាស្រ័យទៅលើអ្វីដែលគាត់ត្រូវការ ឬចូលចិត្តជាង។
- *កុំខ្លាចនឹងផ្តល់ជំនួយ។* ចប់សាលាមិនមែនជាការចប់ការទ្រទ្រង់របស់អ្នកទេ។
- អ្នកអាចយល់ដឹងថែមទៀតអំពីការផ្លាស់ក្នុងធនធានរបស់យើង ឈ្មោះ បង្ហាញកំណត់និងការឆ្លង។

ធ្វើដំណើរអោយបានផ្ទៀងផ្ទាត់

ប្រាប់គេដឹងនូវអ្វីដែលអ្នកត្រូវការ

អ្វីៗនឹងមិនអីទេ

ស្រឡាញ់ខ្លួនឯង(និងអ្នកដទៃ)

អញ្ជើញទៅទៀត

អ្នកនឹងមិនអីទេ

ទទួលស្គាល់ខ្លួនឯង

កុំរិះគន់ខ្លួនឯងពេក

អ្នកអាចធ្វើបាន!

ព័ត៌មានបន្ថែមនិងជំនួយគាំទ្រ

- *ស្តង់ដារពិការភាពសំរាប់ការអប់រំ2005* (https://www.legislation.gov.au/Details/F2005L00767)
- *ច្បាប់រើសអើងពិការភាព1992* (https://www.legislation.gov.au/Details/C2018C00125)
- មជ្ឈមណ្ឌលពិការភាពអូស្ត្រាលី(https://www.disabilityaustraliahub.com.au/) – បញ្ជីអង្គារពិការភាព
- ច្រកផ្លូវពិការភា(https://www.disabilitygateway.gov.au/) – តំណទៅសេវាកម្ម អ្នកគាំទ្រ និងព័ត៌មាន
- គណ:កម្មាធិការសិទ្ធិមនុស្សអូស្ត្រាលី (AHRC) (https://humanrights.gov.au)

https://www.education.gov.au/disability-standards-education-2005/information-resources-students-disability-and-their-caregivers